សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# ការចុះបញ្ជីដីធ្លីនៅកម្ពុជា


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

**-សួរ ចំណាប់**    **-ដាម ឃុនម៉ាលី**

**-ឈុំ វឌ្ឍនា**    **-អ៊ុក ណានី**

**-ជ័រ ចាន់ដារ៉ា**    **-ឈួន ឆានី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**


ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣


**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា

-សេចក្តីផ្តើម ........................................................................ ១
-ផ្នែកទី១៖ ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ.............................................. ២
ក. ស្ថានភាពចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ........................................ ២
ខ. នីតិវិធី............................................................................ ៣
-ផ្នែកទី២៖ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ.............................................. ៥
ក. ស្ថានភាព............................................................................ ៥
ខ. នីតិវិធី ............................................................................ ៦
-ផ្នែកទី៣៖ ការចុះបញ្ជីបំពេញបន្ថែម និងការចុះបញ្ជីបន្ត.................................... ៨
ក. ការចុះបញ្ជីបំពេញបន្ថែម ........................................................... ៨
ខ. ការចុះបញ្ជីបន្ត ................................................................... ៩
សេចក្តីសន្និដ្ឋាន........................................................................ ១១
អនុសាសន៍ ............................................................................ ១៤
ឯកសារយោង

# សេចក្តីផ្តើម

ប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមស៊ីវិលអស់ជាច្រើនទសវត្ស ។ សង្គ្រាមដ៏រ៉ាំរ៉ៃនេះបានធ្វើឲ្យកម្ពុជាទទួលរងនូវការបំផ្លិចបំផ្លាញគ្មានសល់ ជាពិសេសរបបប្រល័យពូជសាសន៍ប៉ុលពត ។ ខ្មែរក្រហមបានលុបបំបាត់ចោលទាំងស្រុងនូវរាល់កម្មសិទ្ធិ ជំនឿ សាសនា ប្រពៃណីដែលធ្លាប់មានកន្លងមក ជាពិសេសរាល់កម្មសិទ្ធិដីធ្លីត្រូវបានដាក់ជាកម្មសិទ្ធិសម្ហូភាព ។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ កម្ពុជាបានខិតខំស្តារនូវរាល់ហេដ្ឋារចនាសម្ព័ន្ធ និង អភិវឌ្ឍន៍សង្គមជាតិឡើងវិញលើគ្រប់វិស័យ។ យ៉ាងណាមិញ របបកម្មសិទ្ធិលើដីធ្លីគឺជាប្រការសំខាន់ដែលប្រទេសកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់រៀបចំជាបណ្តើរៗ ពីដំណាក់កាលមួយទៅដំណាក់កាលមួយរហូតដល់ពេលបច្ចុប្បន្ន ។

បន្ទាប់ពីសាកលភាវូបនីយកម្មដីធ្លីឆ្នាំ១៩៨៩ បញ្ហាវិវាទដីធ្លីបានកើតមានឡើងស្ទើរគ្រប់ទិសទីនៅប្រទេសកម្ពុជា ហេតុនេះហើយបានជាច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងផ្តល់នូវកម្មសិទ្ធិជូនប្រជាពលរដ្ឋ តាមរយៈការចុះបញ្ជីដីធ្លី ដើម្បីឲ្យម្ចាស់កម្មសិទ្ធិលើដីធ្លីទទួលបាននូវការការពារស្របច្បាប់។ ប្រព័ន្ធនៃ ការចុះបញ្ជីដីធ្លីនៅប្រទេសកម្ពុជា ត្រូវបានធ្វើឡើងតាមប្រព័ន្ធ ចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ។ តាមរយៈប្រព័ន្ធនៃការចុះបញ្ជីនេះ តើស្ថានភាពជាក់ស្តែងបង្ហាញឲ្យឃើញ នូវផលវិជ្ជមាន និង ផលអវិជ្ជមានយ៉ាងដូចម្តេចខ្លះ?

# ផ្នែកទី ១៖ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

## ក. ស្ថានភាពចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីដាច់ដោយដុំត្រូវបានចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៨៩ នៅពេលដែលរដ្ឋបាន ផ្តល់នូវឯកជនភាវូបនីយកម្មដីធ្លីដំបូងទៅដល់ប្រជាពលរដ្ឋ ។ ចាប់ពីឆ្នាំ ១៩៨៩ ដល់ ១៩៩៤ ការ ចុះបញ្ជីដាច់ដោយដុំត្រូវបានរដ្ឋផ្តល់សមត្ថកិច្ចទៅឱ្យប្រធានគណៈកម្មការប្រជាជនថ្នាក់ស្រុកជាអ្នក ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីសម្រាប់ដីស្រែចំការ ហើយប្រធានគណៈកម្មការ- ធិការប្រជាជនខេត្ត ថ្នាក់ខេត្តជាអ្នកចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីសម្រាប់ប្រភេទ ដីលំនៅដ្ឋាន ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនៅពេលនោះ ទទួលបានត្រឹមតែប័ណ្ណដែលមានតម្លៃស្មើនឹងប័ណ្ណភោគៈតែប៉ុណ្ណោះ។ នៅក្នុងកំឡុងពេលនោះ ការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំបានទទួលនូវលទ្ធផលចំនួន ៤៨៨.២៧៧ ក្បាលដី ។[1] បន្ទាប់មកនៅក្នុង កំឡុងឆ្នាំ ១៩៩៤ រដ្ឋឈប់ផ្តល់សមត្ថកិច្ចទៅឱ្យការិយាល័យភូមិបាលស្រុក និង ការិយាល័យសុរិយោដីខេត្ត ដោយផ្តល់សមត្ថកិច្ចទៅឱ្យនាយកដ្ឋានសុរិយោដី និង មានការត្រួតពិនិត្យលើពាក្យសុំកាន់កាប់ដីធ្លីពីទីស្តីការគណៈរដ្ឋមន្ត្រី (ឆ្នាំ១៩៩៥)។ ជាលទ្ធផល នៅឆ្នាំ១៩៩៥ ដល់ឆ្នាំ ២០០០ ការចុះបញ្ជីដីធ្លីមានចំនួនធ្លាក់ចុះ (៧០.៣៥៧ក្បាលដី) ។[2] បញ្ហានេះបានបង្ហាញឱ្យឃើញថាការចុះបញ្ជីដីធ្លីមានលក្ខណៈធ្លាក់ចុះ ដោយបញ្ហានៃនីតិវិធីចុះបញ្ជីមានភាពផ្លាស់ប្តូរដែលមានលក្ខណៈស្មុគស្មាញពេកនៅក្នុងការចុះបញ្ជី ។ ដោយឡែក នៅក្នុង ឆ្នាំ២០០០ ដល់ខែមេសា ឆ្នាំ ២០១០ របាយការណ៍នៃការចុះបញ្ជីដីធ្លីមានការកើនឡើងបើធៀបទៅនឹងឆ្នាំ១៩៩៥។ [3] ការកើនឡើងនេះត្រូវបានកំណត់ឃើញថា គឺការកើនឡើងបណ្តាលមកពី ការកើនឡើងនូវតម្លៃដីធ្លីនៅក្នុងឆ្នាំ២០០៧ ហើយក៏ជារយៈពេលមួយដែលវិវាទដីធ្លីបានចាប់ផ្តើមកើនឡើងផងដែរ ទើបបង្កើតឱ្យមានការត្រួតពិនិត្យនៅពាក្យសុំកាន់កាប់ដីតាមរយៈលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីការសុំពិនិត្យ និង ការកែសម្រួលឯកសារពាក់ព័ន្ធ ចុះថ្ងៃទី៧ កញ្ញា ឆ្នាំ១៩៩៤។

ភាពជាប់គាំងនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំបានធ្វើឱ្យលទ្ធផលនៃការចុះបញ្ជីដីធ្លីមានការធ្លាក់ចុះ(ផ្អែកតាមរយៈរបាយការណ៍)នូវចំនួនដ៏ច្រើន។ [4] ការជាប់គាំងនេះត្រូវបានគេសម្លឹងឃើញថា ត្រូវបានកើតឡើងដោយសារបញ្ហាពុករលួយដែលកើតចេញពីការយកថ្លៃការចុះ

[1] ហាប់ ផល្លី, មេរៀននីតិទ្រព្យសម្បត្តិឯកជន (ភ្នំពេញ, ២០១១), ៥៩ ។

[2] ដូច ១, ពី ៤៨៨.២៧៧ ក្បាលដី ទៅ ៧០.៣៥៧ ក្បាលដី។

[3] ដូច ១, ពី ៧០.៣៥៧ ក្បាលដី ទៅ ៧៧.៦៧៤ ក្បាលដី។

[4] ដូច ១

បញ្ជីមានតម្លៃខ្ពស់។ កត្តានេះបានធ្វើឱ្យប្រជាពលរដ្ឋមិនអាចបន្តធ្វើប័ណ្ណបន្តទៀត បង្ខំចិត្តនៅរក្សាដីដោយមិនបានចុះបញ្ជី។ ការជាប់គាំងនេះ ក៏ត្រូវបានកើតឡើងដោយការខ្វះនៅបច្ចេកទេសជំនាញរបស់មន្ត្រីសុរិយោដីផងដែរ ។

## ខ. នីតិវិធី

ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ត្រូវបានធ្វើឡើងទៅលើប្រភេទដីដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ជាមួយការស្នើសុំទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមរយៈមេឃុំចៅសង្កាត់ដែលខ្លួនរស់នៅ ។

បន្ទាប់ពីរដ្ឋបាលសុរិយោដីបានពិនិត្យលើពាក្យស្នើសុំ មានលក្ខណៈគ្រប់គ្រាន់និងសមស្របតាមការកំណត់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវកំណត់ព្រំដី ការវាស់វែង ការវិនិច្ឆ័យ។[5] តែ ក្នុងនេះ ច្បាប់មិនបានបញ្ជាក់អ្វីណាមួយថាជាភាពមិនប្រក្រតីនៃការមិនគ្រប់លក្ខណៈនិងសមស្របរបស់អ្នកដាក់ពាក្យសុំឡើយ។ តាមរយៈការអនុវត្តកន្លងមកការខ្វះនូវចំណេះដឹងរបស់ប្រជាពលរដ្ឋពីការចុះបញ្ជីដីធ្លី (ការបំពេញទម្រង់ពាក្យសុំកាន់កាប់) និងការខ្វះបច្ចេកទេសនៃការមិនបានកំណត់ពីចំណុចនិយាមការច្បាស់លាស់របស់មន្ត្រីសុរិយោដី បានបង្កើតឱ្យមាននូវអ្វីដែលរដ្ឋកំណត់ថាជាភាពមិនប្រក្រតីអាចកើតមានឡើង។ [6] ប្រសិនបើក្បាលដីមិនត្រូវបានកំណត់ពីចំណុចនិយាមការច្បាស់លាស់ទេ តើនៅពេលអនាគតអាចបង្កើតឱ្យមាននូវទំនាស់ដែរឬទេ? បញ្ហានេះអាចនឹងត្រូវបានបង្កើតឱ្យមាននូវភាពស្មុគស្មាញមួយ នៅពេលណាមានការរំលោភបំពានមួយបានកើតឡើង។

នៅពេលដែលការពិនិត្យភាពច្បាស់លាស់ និង ប្រតិបត្តិការនូវបច្ចេកទេស ការកំណត់ព្រំការវាស់វែងនិងការបិទផ្សាយត្រូវបានបញ្ចប់រដ្ឋបាលសុរិយោដីថ្នាក់ខេត្តត្រូវបញ្ជូនឯកសារទាំងនោះ ឱ្យពិនិត្យលើភាពត្រឹមត្រូវ និង គ្រប់គ្រាន់នៃឯកសារទាំងអស់ រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល និងខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មអំណាចពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។[7] ផ្អែកតាមស្ថានភាពជាក់ស្តែងពីការទទួលបានប័ណ្ណរបស់ប្រជាពលរដ្ឋគឺពុំឃើញមាននូវប្រជាពលរដ្ឋណាម្នាក់ ទទួលបាននូវប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុ នោះទេ គឺទទួលបានត្រឹមតែប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ឬ ហៅថាប័ណ្ណភោគៈតែប៉ុណ្ណោះចំពោះ លទ្ធផលសរុបទាំងអស់នៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ។[8]

---

[5] អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ លេខ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០០២, មាត្រា៨ វាក្យខ័ណ្ឌទី៣, ៤ ។

[6] "ការពិព័ណនាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំ", មាត្រា ៧ កថាខ័ណ្ឌទី២ នៃអនុក្រឹត្យនៅចំណុច ៥ខាងលើ។

[7] មាត្រា ៧ នៃអនុក្រឹត្យ ចំណុច ៥ ។

[8] ក្បាលដីចុះបញ្ជីទាំងអស់ ៦០១.៣៥៦ ក្បាលដី ចាប់ពីឆ្នាំ ១៩៨៩ ដល់ខែឧសភា ឆ្នាំ២០១២ "លោកសាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្វី, សៀវភៅ នីតិទ្រព្យសម្បត្តិឯកជន, ភ្នំពេញ ២០១១។

## ផ្នែកទី២ ៖ ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ

ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ គឺជាប្រតិបត្តិការចុះបញ្ជីលើក្បាលដីដែលបានកំណត់ជាតំបន់វិនិច្ឆ័យហើយនោះ។ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធធ្វើឡើងដោយគំរោងស្ថាប័នរដ្ឋាភិបាលជូនដល់ពលរដ្ឋដែលមានលក្ខណៈជាទ្រង់ទ្រាយធំ ក្នុងគោលដៅដើម្បីចេញប័ណ្ណកម្មសិទ្ធិជូនពលរដ្ឋ និង ងាយស្រួលក្នុងការគ្រប់គ្រង ចាត់ចែងដែនដីនគរូបនីយកម្មរបស់ខ្លួន ប្រកបដោយសុវត្ថិភាព។

### ក. ស្ថានភាពនៃការចុះបញ្ជី

បន្ទាប់ពីការបង្កើតឱ្យមានការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ នៅថ្ងៃទី១៩ខែឧសភា ឆ្នាំ២០០២ ការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធបានចាប់ផ្តើមឡើងក្រោមគម្រោង រៀបចំដែនដី និងរដ្ឋបាលដីធ្លី សម្រាប់ដំណាក់កាលដំបូងមានរយៈពេល៥ឆ្នាំ ។ គម្រោងរៀបចំដែនដី និង រដ្ឋបាលដីធ្លីនេះត្រូវបានធ្វើឡើងក្រោមការជួយឧបត្ថមពីដៃគូរជំនួយមួយចំនួន ដែលរួមមានរាជ- រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារពិភពលោក (World Bank) រដ្ឋាភិបាលអាល្លឺម៉ង់ តាមរយៈ GTZ ហើយនឹងអង្គការ FINNMAP ដែលបានជំនួយ ពីរដ្ឋាភិបាលហ្វាំងឡង់។

នៅក្នុងរបាយការណ៍ បានបង្ហាញពីលទ្ធផលនៃការចុះបញ្ជីជាប្រព័ន្ធ នៅក្នុងឆ្នាំ ២០០២ រហូតដល់ ខែកញ្ញា ឆ្នាំ២០០៨ ដែលការចុះបញ្ជីបានទៅដល់ ៩០២.៩៦៨ ប័ណ្ណ (ក្បាលដី)។[9] លុះដល់ ខែតុលា ឆ្នាំ ២០០៨ រហូតដល់ ខែមេសា ឆ្នាំ២០១០ បានឃើញថាលទ្ធផលមានការប្រែប្រួលយ៉ាងច្រើន។[10] កត្តានេះ ត្រូវបានកើតឡើងដោយហេតុថា នៅក្នុងឆ្នាំ ២០០២ ដល់ ឆ្នាំ ២០០៨ រដ្ឋាភិបាលបានទទួលជំនួយពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការមួយចំនួនផ្សេងៗទៀត ដែលធ្វើឱ្យរដ្ឋមានថវិកាក្នុងការដំណើការនូវការចុះបញ្ជី។ ក្រោយមករដ្ឋាភិបាលកម្ពុជាបានឈប់ ទទួលយកនូវជំនួយ(ឆ្នាំ ២០០៩)ដោយមិនដឹងមូលហេតុ។

ក្រោយមកទៀត នៅខែ ឧសភា ឆ្នាំ២០១០ ដល់ខែមេសា ឆ្នាំ ២០១១ លទ្ធផលនៃការចុះបញ្ជី ក៏នៅតែមានការធ្លាក់ចុះបន្តទៀត ដោយសារការខ្វះខាតនូវថវិកាក្នុងការដំណើរការនូវការចុះបញ្ជី។ នៅក្នុងកំឡុងពេលនេះ កត្តាមួយចំនួនទៀតក៏បានធ្វើឱ្យមានការថយចុះនូវលទ្ធផលនៃការ

[9] របាយការណ៍ស្តីពី លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី ចាប់តាំងពីថ្ងៃចាប់ផ្តើម រហូតដល់ ខែ ឧសភា ឆ្នាំ២០១២ របស់រាជធានី/ខេត្ត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១២ និង ឯកសារ នីតិទ្រព្យសម្បត្តិឯកជន របស់សាស្ត្រាចារ្យ ហាប់ ផល្វី ភ្នំពេញ ២០១១។

[10] ចាប់ពី ៩០២៩៦៨ ប័ណ្ណ ធ្លាក់ទៅដល់ ៥១៥០០៣ ប័ណ្ណ ។

ចុះបញ្ជីនោះគឺភាពជាប់គាំងនៃមន្ត្រីសុរិយោដី ដោយការខ្វះនូវជំនាញ និង ការកើតមានឡើងនូវអំពើពុករលួយ ។ បញ្ហាទាំងនេះ ជាផលវិបាកមួយដែលធ្វើឱ្យការចុះបញ្ជីមានការកកស្ទះ និង មិនអាចអនុវត្តទៅមុខបន្តទៅទៀត ។

បើមើលទៅរយៈកន្លងទៅថ្មីៗនេះ ឃើញមានការចុះបញ្ជីជាប្រព័ន្ធដោយក្រុមយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ ហ៊ុន សែន បានធ្វើយុទ្ធនាការក្នុងការចុះបញ្ជីនូវដីធ្លីដែលមិនទាន់បានចុះ បញ្ជី។ យុទ្ធនាការនេះ បានធ្វើឱ្យប្រជាពលរដ្ឋអាចទទួលបាននូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងទទួលបានលទ្ធផលនៃការចុះបញ្ជីកើតឡើងផងដែរ។ តែក្រោយមក គម្រោងចុះបញ្ជីដីដោយក្រុមយុវជនស្ម័គ្រចិត្តនេះ ត្រូវបានបញ្ចប់ដោយមិនដឹងពីមូលហេតុនយោបាយ ឬ រដ្ឋបាលណាមួយនោះទេ?

## ២. នីតិវិធី

ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធនឹងត្រូវអនុវត្ត ទៅលើគ្រប់ក្បាលដី (ទាំងដីរដ្ឋ ទាំងដី ឯកជន) ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ ពោលគឺបន្ទាប់ពីមានការឯកភាពពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អំពីការជ្រើសទីតាំងតំបន់រួចមកអភិបាលខេត្ត រាជធានីនឹងចេញប្រកាស កំណត់តំបន់ និង ព្រំប្រទល់នៃការធ្វើវិនិច្ឆ័យ។[11] ពលរដ្ឋដែលមានដីនៅក្នុងតំបន់វិនិច្ឆ័យត្រូវរួម សហការ និង ដាក់ពាក្យតាមទំរង់បែបបទដើម្បីទទួលបានប័ណ្ណកម្មសិទ្ធ (ប័ណ្ណភោគៈ)។

ក្រោយពីបានកំណត់តំបន់វិនិច្ឆ័យមន្ត្រីជំនាញរបស់រដ្ឋ នឹងត្រូវចាប់ផ្តើមប្រតិបត្តិការចុះបញ្ជីលើក្បាលដី ព្រមទាំងចេញប័ណ្ណកម្មសិទ្ធិស្ថាពរដល់ម្ចាស់ក្បាលដីក្នុងតំបន់ ដែលត្រូវបានធ្វើការវិនិច្ឆ័យនោះទាំងអស់ ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អាចធ្វើការចុះបញ្ជីក្បាលដីពីតំបន់មួយទៅតំបន់មួយ ដែលគេបានកំណត់ថាជាតំបន់វិនិច្ឆ័យ រហូតទាល់តែក្បាលដីទាំងអស់នៅទូទាំងប្រទេសត្រូវបានចុះបញ្ជីទៅក្នុងសៀវភៅគោលបញ្ជីដីធ្លីចប់សព្វគ្រប់ ។ នីតិវិធីនៅក្នុងការរៀបចំការជាក់ស្តែង រដ្ឋត្រូវការនូវធនធានមន្ត្រីជំនាញរបស់ខ្លួនអោយបានគ្រប់គ្រាន់ជាជាងការប្រើប្រាស់នូវធនធានដែលគ្មានជំនាញច្បាស់លាស់ ។ ជាក់ស្តែងរដ្ឋាភិបាលបានប្រើប្រាស់នូវកំលាំងយុវជនស្ម័គ្រចិត្តអោយចុះវាស់ដីធ្លីក្នុងនីតិវិធីនៃការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ ។ ទង្វើនេះជាការស្តែងចេញនូវការទាត់ចោលនូវមន្ត្រីជំនាញដែលទទួលបន្ទុកក្នុងកិច្ចការនេះ។ បៀវត្សគឺជាផ្នែកមួយដ៏សំខាន់សម្រាប់មន្ត្រីជំនាញ ក្នុងការប្រតិបត្តិការតួនាទីរបស់ខ្លួន។ ជាក់ស្តែងបៀវត្សមិនគ្រប់គ្រាន់ធៀបនឹងអតិផរណានៃសេដ្ឋកិច្ច បង្ខំចិត្តអោយមន្ត្រីជំនាញរៃអង្គាសថវិកាជំនួយផ្សេងៗ

[11] មាត្រា ២ នៃអនុក្រឹត្យលេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

ទៀតនៅក្នុងនីតិវិធីនៃការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធនេះ បង្កលក្ខណៈអោយពលរដ្ឋមិនសប្បាយចិត្តនៅក្នុងការចូលរួមជាដើម ។ នៅក្នុងប្រតិបត្តិការមន្ត្រីជំនាញត្រូវការនូវឧបករណ៍ទំនើបដូចជាម៉ាស៊ីន GPS ទំនើបដែលមានកម្រិតលំអៀងតិចដែលអាចទទួលយកបាន តែបើសិនជាមន្ត្រីជំនាញប្រើប្រាស់នៅឧបករណ៍ដែលមានកម្រិតទាប គុណភាពពិបាកទទួលយក លទ្ធផលគឺពិតជាពិបាកទទួលយកមិនខាន ហើយនឹងមានការជំទាស់ពីសំណាក់ពលរដ្ឋដែលជាហេតុអោយមានការយឺតយ៉ាវក្នុងការចេញប័ណ្ណកម្មសិទ្ធិ ។ បើពិនិត្យមើលអោយជាក់ស្តែងទៅលើនីតិវិធីនៃការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធនេះ មានភាពស្មុគស្មាញ និង វែងអន្លាយនៅឡើយដែលជាហេតុធ្វើអោយរាំងស្ទះដល់លទ្ធផលដែលសម្រេចនៃបានរបស់គំរោងរដ្ឋាភិបាលលើការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធនេះ។ មួយវិញទៀតពលរដ្ឋ ហាក់បីដូចជាមិនពេញចិត្តចំពោះនីតិវិធីដ៏វែងអន្លាយនេះទេ។

## ផ្នែកទី៣៖ ការចុះបញ្ជីបំពេញបន្ថែម និង ការចុះបញ្ជីបន្ត

ដោយមើលឃើញពីការគ្រប់គ្រងនិងការកាន់កាប់ឯកសារ នៅមិនទាន់មានការឯកភាពគ្នានៅឡើយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ បានចេញនូវសារាចរណ៍ណែនាំស្តីពីការចុះបញ្ជីបំពេញបន្ថែម និង សេចក្តីណែនាំស្តីពីការចុះបញ្ជីបន្ត ក្នុងគោលបំណងដើម្បីពង្រឹងនូវការកាន់កាប់ឯកសារទាំងនេះឲ្យកាន់តែមានភាពសុក្រឹត ។

### ក. ការចុះបញ្ជីបំពេញបន្ថែម

ការចុះបញ្ជីបំពេញបន្ថែមជាការចុះបញ្ជីដែលត្រូវបានបង្កើតឡើង ដើម្បីបំពេញនូវភាពខ្វះចន្លោះដែលក្រោយពីបានបញ្ចប់នីតិវិធីចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ម្ចាស់នៃក្បាលដីមួយចំនួនមិនបានចូលរួមមកបំពេញបែបបទតាមកាលកំណត់ និង ក្បាលដីមួយចំនួនបានកាន់កាប់ត្រឹមត្រូវតែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិនៅឡើយ ។[12]

### នីតិវិធី

នៅក្នុងនីតិវិធីនៃការចុះបញ្ជីបំពេញបន្ថែមនេះ គឺដូចគ្នាទៅនឹងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ គឺម្ចាស់ដីត្រូវដាក់ពាក្យស្នើសុំទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាល តាមរយៈមេឃុំចៅសង្កាត់ដែលទីតាំងដីនោះបិតនៅ។ បន្ទាប់មកការិយាល័យជំនាញចុះត្រួតពិនិត្យបច្ចេកទេស និងកំណត់ព្រំវាស់វែង កសាងនិងប្រមូលទិន្នន័យ រួចធ្វើការបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបាននៅឃុំសង្កាត់ និង នៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ។ ជាចុងក្រោយ ការចុះបញ្ជី និង ការចេញប័ណ្ណគឺជាសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដោយធ្វើការ ចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី និង ក្នុង Digital file ហើយបោះពុម្ពប័ណ្ណ ចុះហត្ថលេខា រួចប្រគល់ជូនអ្នកស្នើសុំ ។

ការចេញនូវសារាចរណ៍ណែនាំស្តីពីការចុះបញ្ជីបំពេញបន្ថែមនេះ បានឆ្លុះបញ្ចាំងឲ្យឃើញ ពីភាពខ្វះចន្លោះនិងភាពទន់ខ្សោយរបស់ប្រព័ន្ធនៃការចុះបញ្ជីដីធ្លី ។ ជាក់ស្តែងតាមរយៈការចុះ បញ្ជីមានលក្ខណៈជាប្រព័ន្ធ និង ដាច់ដោយដុំ ម្ចាស់នៃក្បាលដីមួយចំនួនមិនបានចូលរួម និង មិនមានការសហការល្អជាមួយអាជ្ញាធរ ដែលជាហេតុនាំឲ្យការចុះបញ្ជីនេះពុំទទួលបាននូវលទ្ធផល

[12] ហាប់ ផល្លី, កម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងដីធ្លី (ភ្នំពេញ, ២០១០), ៨២៥ ។

ប្រសើរឡើយ ។ ហេតុនេះហើយទើបនៅឆ្នាំ២០០៦ មានការចេញនូវសារាចរណ៍ណែនាំស្តីពីការចុះបញ្ជីបំពេញបន្ថែមដើម្បីបំពេញនូវភាពខ្វះខាតទាំងនេះ ។ ទោះបីជាមានការចុះបញ្ជីបំពេញបន្ថែមនេះក៏ដោយក៏លទ្ធផលនៃការចុះបញ្ជីនៅតែមិនមានការកើនឡើងគួរឲ្យកត់សម្គាល់ដែរ។ជាក់ស្តែងលទ្ធផលនៃការចុះបញ្ជីបំពេញបន្ថែមតាំងពីចាប់ផ្តើមដល់ខែឧសភា២០១២ មានត្រឹមតែ២៧៥ក្បាលដីប៉ុណ្ណោះ ។[13]

ម្យ៉ាងវិញទៀត ការចុះបញ្ជីបំពេញបន្ថែមនេះ ក៏មិនបានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ដែរ ។ ការមិនបានចែងនេះ គឺមកពីច្បាប់កំនត់នីតិវិធីនៃការចុះបញ្ជីមានតែពីរប្រភេទគឺ ការចុះ បញ្ជីជាប្រព័ន្ធ និង ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ហើយគេក៏ពុំបានគិតនិងប្រមើលមើល ពីផលអវិជ្ជមានដែលនឹងកើតមានឡើងក្រោយពីការអនុវត្តការចុះបញ្ជីនេះ ។ ជាមួយគ្នានេះផងដែរ ការខកខានមិនបានចែងពីការចុះបញ្ជីបំពេញបន្ថែមនេះ ក៏សរបញ្ជាក់ឲ្យឃើញថាការតាក់តែងច្បាប់នៅមានចន្លោះប្រហោង មិនមានការគិតគូរឲ្យបានវែងឆ្ងាយមុននឹងបង្កើតច្បាប់ឡើង។

## ខ. ការចុះបញ្ជីបន្ត

ការចុះបញ្ជីបន្តជាប្រភេទនៃការចុះបញ្ជីមួយ ដែលកើតឡើងដោយសារចរន្តការផ្លាស់ប្តូរ ប្រែប្រួលនៃកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើដីធ្លី ។ ការចុះបញ្ជីបន្តអាចកើតឡើងតាមរយៈរូបភាពច្រើនយ៉ាងតាមរយៈកិច្ចសន្យាការលក់ កិច្ចសន្យាដូរ កិច្ចសន្យាឲ្យ កិច្ចសន្យាជម្រះមតិក ការបំបែកក្បាលដី សេចក្តីសម្រេចរបស់តុលាការ ការប្រែប្រួល លក្ខណៈរូបនៃក្បាលដីជាដើម។[14] ការប្រែប្រួល ឬកិច្ចសន្យា ឬសេចក្តីសម្រេចរបស់តុលាការទាំងនេះហើយដែលនាំទៅដល់ការចុះបញ្ជីដែលជាកត្តាចាំបាច់មួយសម្រាប់អ្នកកាន់កាប់ដីទាំងឡាយក្នុងការតតាំងជាមួយតតិយជន នៅពេលដែលមានវិវាទកើតឡើង ។

### ១. ការចុះបញ្ជីបន្តតាមរយៈកិច្ចសន្យា

ការចុះបញ្ជីបន្តតាមរយៈកិច្ចសន្យាដែលនាំទៅដល់ការផ្ទេរសិទ្ធិ ដូចជាកិច្ចសន្យាលក់ ដូរ ឲ្យជាដើមនោះអាចប្រព្រឹត្តទៅបានហើយតតិយជនមិនអាចជំទាស់ លុះត្រាតែលិខិតផ្ទេរសិទ្ធិនោះធ្វើឡើងតាមរូបមន្តយថាភូត ដោយបុគ្គលដែលមាននីតិសម្បទា និង ត្រូវបានចុះបញ្ជីនៅអង្គភាព

---

[13] របាយការណ៍ ស្តីពី លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី ចាប់តាំងពីថ្ងៃចាប់ផ្តើម រហូតដល់ ខែ ឧសភា ឆ្នាំ២០១២ របស់រាជធានី/ខេត្ត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១២ ។

[14] ហាប់ ផល្លី, កម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងដីធ្លី (ភ្នំពេញ, ២០១០), ៦៧៧ ។

សុរិយោដី។[15] នេះសរឲ្យឃើញថាការទិញ លក់អចលនវត្ថុ មិនមែនចេះតែអាចទៅតាមតែអំពើចិត្ត នោះទេ វាទាមទារឲ្យបំពេញនូវលក្ខខណ្ឌច្បាប់ ព្រោះរាល់ការលក់ទិញនឹងនាំទៅដល់ការផ្ទេរសិទ្ធិ ដែលមិនអាចបញ្ចប់ដោយត្រឹមតែការប្រគល់លុយ និង ប្រគល់វត្ថុទៅវិញទៅមកនោះទេ ហើយចាំបាច់ត្រូវតែចុះបញ្ជីនៅអង្គភាពសុរិយោដីថែមទៀត ទើបមានសិទ្ធិពេញលេញទៅតាមច្បាប់ ។

តាមភាពជាក់ស្តែង ម្ចាស់អចលនវត្ថុភាគច្រើនធ្វើការទិញលក់ ត្រឹមតែ ឃុំ សង្កាត់ ឬ ខណ្ឌ តែប៉ុណ្ណោះ មិនបានធ្វើការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិទៅឈ្មោះអ្នកទិញឡើយ ដោយសារតែគាត់ពុំបានគិតដល់ផលវិបាកដែលកើតមាននាពេលអនាគត ជាពិសេសនៅពេលដែលមានវិវាទកើតឡើង ។ បញ្ហាសំខាន់មួយទៀតគឺប្រជាជនគាត់បានដឹងហើយពីបញ្ហានីតិវិធីចុះបញ្ជីបន្តនេះ តែគាត់មានការរារែកក្នុងការទៅចុះបញ្ជីដោយហេតុថាការបង់ពន្ធ ប្រថាប់ត្រាមានអត្រាខ្ពស់រហូតដល់ ៤ ភាគរយ ហើយនីតិវិធីមានការយឺតយ៉ាវប្រសិនបើមិនមានសោហ៊ុយបន្ថែមខាងក្រៅ។ ករណីនេះ ប្រសិនបើមានការលក់ទិញបន្តច្រើនគ្នាហើយអ្នកទិញចុងក្រោយគាត់ចង់ធ្វើការកាត់ឈ្មោះផ្ទេរសិទ្ធិមកឈ្មោះគាត់ តើគាត់អាចទទួលយកបានទេចំពោះការបង់ពន្ធជំនួសអ្នកមុនៗ?

### ២. ការចុះបញ្ជីបន្តក្រៅពីកិច្ចសន្យា

ការចុះបញ្ជីបន្តក្រៅកិច្ចសន្យា ភាគច្រើនទាក់ទងទៅនឹងសេចក្តីសម្រេចរបស់តុលាការ ឬ ការប្រែប្រួលទ្រង់ទ្រាយនៃក្បាលដីដោយធម្មជាតិជាដើម។ ចំពោះការចុះបញ្ជីដែលទាក់ទងទៅនឹងសេចក្តី សម្រេចរបស់តុលាការដូចជា សាលក្រម សាលដីកា គឺធ្វើឡើងដោយក្រឡាបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត។ ចំណែកការប្រែប្រួលនៃក្បាលដីក៏តម្រូវឲ្យម្ចាស់ក្បាលដីទៅធ្វើការចុះ បញ្ជីដែរដើម្បីការពារនូវទំហំដីរបស់គាត់ទៅតាមផ្លូវច្បាប់ ។

ភាពជាក់ស្តែង ការចុះបញ្ជីបន្តនេះ ឃើញថាពុំទាន់ត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយទេ ដោយសារនៅក្នុងសេចក្តីណែនាំស្តីពីការចុះបញ្ជីបន្តបានកំនត់ណែនាំឲ្យមន្ត្រី ក៏ដូចជាថ្នាក់ដឹកនាំទទួល បន្ទុកឲ្យខិតខំយកចិត្តទុកដាក់ក្នុងការកសាងឯកសារជាមូលដ្ឋាន និងពង្រឹងការចុះបញ្ជីទាំងអស់ឲ្យកាន់តែមានប្រសិទ្ធភាព ហើយទិន្នន័យនៃការចុះបញ្ជីទាក់ទងនឹងការបង្រួមក្បាលមានអ-ត្រាទាបនៅឡើយត្រឹមតែជិត២០០ ក្បាលដីគិតតាំងពីចាប់ផ្តើមរហូតដល់ខែឧសភា ឆ្នាំ២០១២។[16]

---

[15] ហាប់ ផល្លី, កម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងដីធ្លី (ភ្នំពេញ, ២០១០), ៦៧៧ ។

[16] របាយការណ៍ ស្តីពី លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី ចាប់តាំងពីថ្ងៃចាប់ផ្តើម រហូតដល់ ខែ ឧសភា ឆ្នាំ២០១២ របស់រាជធានី/ខេត្ត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១២ ។

# សេចក្តីសន្និដ្ឋាន

ការចុះបញ្ជីដីធ្លីនៅកម្ពុជា បានបង្ហាញឲ្យឃើញនូវលក្ខណៈល្អប្រសើរនៃបទប្បញ្ញត្តិច្បាប់និងនីតិវិធីក្នុងការចុះបញ្ជីដីធ្លី ប៉ុន្តែក៏បានបង្ហាញពីភាពមិនស៊ីចង្វាក់គ្នារវាងបទប្បញ្ញត្តិ និង ការអនុវត្តផងដែរ ជាហេតុផលមួយបង្កើតឱ្យមាននូវភាពមិនប្រក្រតីកើតឡើង។ ប្រព័ន្ធនៃការចុះបញ្ជីទាំងអស់ខាងលើមិនត្រឹមតែធ្វើឲ្យកើតមាននូវភាពមិនប្រក្រតីនេះទេ តែបង្ហាញពីភាពមិនយល់ច្បាស់ជាមួយនឹងការខ្វះនូវបច្ចេកទេសរបស់មន្ត្រីជំនាញក្នុងការអនុវត្តមុខងារនេះផងដែរ ។

ទាក់ទងនឹងការចុះបញ្ជី ដែលមានលក្ខណៈដាច់ដោយដុំ ឃើញថាការអនុវត្តដែលទាក់ទងនឹងបទប្បញ្ញត្តិមានការបញ្ញត្តិនូវនីតិវិធីបានយ៉ាងមុតស្រួច និង ច្បាស់លាស់ចំពោះនីតិវិធីនីមួយៗរហូតដល់ការចេញប័ណ្ណ ប៉ុន្តែនៅក្នុងចំណុចមួយចំនួននៅក្នុងនីតិវិធី មានការខ្វះខាតទាក់ទងវិធានការផ្សព្វផ្សាយនូវច្បាប់ជាមុន មុននឹងអនុវត្តនូវបទប្បញ្ញត្តិនៃការចុះបញ្ជីប្រភេទនេះ។ ការទាមទារប្រភេទនេះ ដោយហេតុថានៅក្នុងស្ថានភាពជាក់ស្តែង មានការខ្វះនូវសមត្ថភាពក្នុងការបំពេញ និងការយល់ដឹងនូវចំណុចខ្លះនៅក្នុងការបំពេញពីសំណាក់ប្រជាពលរដ្ឋ។ ឯមួយវិញទៀតទាក់ទងនឹងបញ្ហានៃការអនុវត្តខុសគ្នាទៅនឹងការបញ្ញត្តិរបស់ច្បាប់ ក្នុងការចំណាយថ្លៃសេវានៃការចុះបញ្ជីដីធ្លី។ ភាពជាក់ស្តែងនៃការចុះបញ្ជីត្រូវមានការចំណាយយ៉ាងច្រើន។[17] ច្បាប់បានកំណត់ត្រឹមតែ ៣៥០.០០០ រៀល ចំពោះដីដែលស្ថិតនៅរាជធានី និងទីប្រជុំជនតែប៉ុណ្ណោះ ។ កត្តានេះ ជាហេតុមួយដែលធ្វើឱ្យការចុះបញ្ជីដីធ្លីដាច់ដោយដុំមានការធ្លាក់ចុះ។ បញ្ហាមួយទៀត ដែលឃើញមានកើតឡើងរួចមកហើយនោះ គឺការចុះបញ្ជីប្រភេទនេះមិនទាន់បានទទួលនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បានទទួលត្រឹមតែប័ណ្ណសម្គាល់កាន់កាប់អចលនវត្ថុ (ប័ណ្ណភោគ:)ប៉ុណ្ណោះ។

ចំពោះការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធវិញ ដែលជាប្រតិបត្តិការធ្វើឡើងដោយថវិការបស់រដ្ឋរួមជាមួយនឹងការចូលរួមពីអ្នកកាន់កាប់នោះ មានការកំណត់នូវនីតិវិធីមួយសមស្របដែលអាចធ្វើឱ្យប្រជាពលរដ្ឋអាចទទួលបាននូវភាពងាយស្រួល រួមជាមួយការទុកចិត្ត តែទោះជាយ៉ាងនេះក្តីបញ្ហាប្រឈមនៅតែមានកើតចេញពីការមិនអនុវត្តមុខងារឱ្យស្របទៅតាមគោលការណ៍ច្បាប់រួមជាមួយការខ្វះទាំងបច្ចេកទេស និង ជំនាញរបស់មន្ត្រី ជាកត្តាមួយដែលធ្វើឱ្យមានការ កកស្ទះ ។

[17] ចំណាយជាក់ស្តែង រហូតទៅដល់ ២០០០ ទៅ ២៥០០ ដុល្លា ។

ការចុះបញ្ជីបំពេញបន្ថែម គ្រាន់តែជាយន្តការមួយបន្ថែមទៅលើប្រព័ន្ធនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និង ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ហើយបានបង្ហាញពីភាពខ្វះចន្លោះនៃការចុះបញ្ជីដីធ្លី ។

ចំណែកឯការចុះបញ្ជីបន្តក៏មិនទាន់បានទទួលលទ្ធផលល្អដែរ ដោយសារប្រជាជនមិនទាន់យល់ច្បាស់ពីផលប៉ះពាល់នៃការមិនបានផ្ទេរកម្មសិទ្ធិ ហើយអត្រានៃការបង់ពន្ធប្រថាប់ត្រានៅមានតម្លៃខ្ពស់ ។

# អនុសាសន៍

នៅក្នុងការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ រដ្ឋាភិបាលគួរតែគួរតែពង្រឹងនូវសមត្ថភាព ក៏ដូចជាក្រមសីលធម៌របស់មន្ត្រីជំនាញក្នុងអនុវត្ត និង ការបំពេញមុខងាររបស់ខ្លួនឱ្យកាន់តែមានភាពប្រសើរឡើង ដោយធ្វើការបណ្តុះបណ្តាលទៅដល់មន្ត្រីជំនាញ រួមជាមួយប្រជាពលរដ្ឋ ឱ្យបានយល់ច្បាស់នូវស្ថានភាពផ្លូវច្បាប់ឱ្យកាន់តែច្បាស់។ រួមជាមួយគ្នានេះ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់គួរណាបង្កើតឱ្យមាននូវចំណុចនិយាមការច្បាស់លាស់ ចៀសវៀងការបង្កើតឱ្យមាននូវភាពមិនប្រក្រតី។

ការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ រដ្ឋាភិបាលគួរណាតែស្វែងរកនូវថវិកាដោយស្វ័យភាព ជាជាងទទួលហិរញ្ញប្បទានពីបរទេសដោយបង្កើននូវខ្ទង់ថវិកា ក្នុងគោលដៅកំណត់ណាមួយដើម្បីធ្វើឱ្យដីនៅកម្ពុជាទាំងអស់អាចទទួលបាននូវប័ណ្ណកម្មសិទ្ធិ ។ រដ្ឋាភិបាលគួរណាពង្រឹងនូវ មន្ត្រីជំនាញដែលមានស្រាប់ ជាជាងណាបង្កើតនូវអង្គភាព ឬ ក្រុមការងារផ្សេងមួយទៀតដែល គ្មានជំនាញអាចនាំឱ្យមានការបង្កឱ្យមានវិវាទសមត្ថកិច្ច ។

រាជរដ្ឋាភិបាលគួរតែពង្រឹងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ជំនួសឲ្យការចុះបញ្ជីបំពេញបន្ថែម ព្រោះនីតិវិធីគឺដូចគ្នាទាំងស្រុង ដោយអាចបង្កើតឲ្យមានជាកញ្ចប់ថវិកាមួយសម្រាប់មន្ត្រីដែលចុះវាស់វែង និង មន្ត្រីពាក់ព័ន្ធទាំងអស់ នៅពេលគាត់ចុះធ្វើការងារនេះ ព្រមទាំងបញ្ជាប្រាក់បៀវត្សឲ្យសក្តិសមទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីចៀសវាងនូវភាពពុករលួយមួយចំនួនកើតឡើង ។

ចំពោះការចុះបញ្ជីបន្ត រាជរដ្ឋាភិបាលគួរកាត់បន្ថយអត្រាពន្ធប្រថាប់ត្រាឲ្យបានទាបជាង៤ភាគរយឬអាចនៅសល់ត្រឹម១ភាគរយ ដើម្បីទុកលទ្ធភាពឲ្យប្រជាជនបានទៅធ្វើការកាត់ឈ្មោះផ្ទេរសិទ្ធិបានគ្រប់គ្នា ហើយទទួលបាននូវការការពារស្របច្បាប់ ព្រោះច្បាប់ការពារតែអចលនវត្ថុទាំងឡាយណាដែលបានចុះបញ្ជីត្រឹមត្រូវប៉ុណ្ណោះ ។

# ឯកសារយោង


ក្រមរដ្ឋប្បវេណី. ២០០៧. ភ្នំពេញ ។

ច្បាប់ភូមិបាល. ២០០១. ភ្នំពេញ ។

អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ /បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ។

អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ លេខ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។

សារាចរណែនាំអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ) លេខ ០០១ ដនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២។

សារាចរណែនាំអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ លេខ០១ដនស/សជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤។

សារាចរណែនាំស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម លេខ០៦ សណន ចុះថ្ងៃ ទី០៥ ខែឧសភា ឆ្នាំ២០០៦។

សេចក្តីសម្រេចស្តីពីសេវាសុរិយោដី លេខ៥១សសរ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦។

សេចក្តីណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី លេខ១១សណន ចុះថ្ងៃទី២១កក្កដាឆ្នាំ២០០៦។

សេចក្តីណែនាំស្តីពីវិធីកែតម្រូវឯកសារផ្លូវការ និង Digital សម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ) លេខ២៧៣/អសដក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧។

សេចក្តីណែនាំស្តីពីការចុះបញ្ជីបន្ត លេខ ០២ដនស/សជ ២៨ ខែឧសភា ឆ្នាំ២០០៤។

ប្រកាសអន្តរក្រសួងលេខ៥៩ ប្រក.ដ.ន.ស. ០៣ ខែឧសភា ឆ្នាំ២០១១. ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី . ភ្នំពេញ ។

របាយការណ៍ស្តីពីលទ្ធផលនៃការចុះបញ្ជីដីធ្លី លេខ៤១៩ LASSP. ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ហាប់ ផល្វី. ២០១០. កម្រងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី. ភ្នំពេញ ។